ក្រសួងអប់រំ យុវជន និង កីឡា

# ១ ព័ត៌មានជាមូលដ្ឋាន

## បញ្ឈប់ពលកម្មកុមារ

### ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧



## គោលបំណង :

ផ្តល់ព័ត៌មានអំពីសាវតាពលកម្មកុមារដែលជាមូលដ្ឋានគ្រឹះសម្រាប់ យល់ដឹងនូវបញ្ហាស្មុគស្មាញ ដែលកើតឡើងជុំវិញយើង ។



## លទ្ធផលរំពឹងទុក :

ជំរុញឱ្យមានការយកចិត្តទុកដាក់ទៅលើក្មេងៗ ហើយញុំាងឱ្យមាន ប្រតិកម្មទាន់ពេលវេលា ឆ្លើយតបដោយប្រើប្រាស់ព័ត៌មានស្ថិតិប្រកបដោយ ប្រសិទ្ធភាពតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (Visual Media )ដើម្បីពណ៌នា អំពីពលកម្មកុមារក្នុងបរិយាកាសរបស់ពួកគេ។

## ការកំណត់ពេលវេលា :

បង្រៀនពីពេលជាប់គ្នា ឬក៏ពីរពេលដាច់ពីគ្នា

## ហេតុផល :



យោងតាមការប្រមាណរបស់អង្គការពលកម្មអន្តរជាតិ (ILO) ថ្មីៗនេះ មានកម្មករកុមារជាង ២៤៥ លាននាក់ក្នុងពិភពលោក ដែលមានអាយុតិចជាង ១៨ឆ្នាំ។ ប្រហែលជា១៧៩លាននាក់នៃកុមារទាំងនោះកំពុងស្ថិតក្នុងស្ថានភាព មួយដ៏អាក្រក់បំផុត។

ជាមួយគ្នានេះដែរ ប្រទេសអាហ្វ្រិច (Sub Saharan Africa) អាស៊ី និងប៉ាស៊ីហ្វិច ក្នុងចំណោមកុមារដែល គេជួលឱ្យមកធ្វើការមានកុមារ៨៣%ដែល មានអាយុពី៥ឆ្នាំដល់១៤ឆ្នាំ ។ កម្មករកុមារភាគច្រើនពុំបានរៀនសូត្រ ហើយ ពួកគេបានរងការឈឺចាប់ខាងផ្លូវចិត្ត ខាងរាងកាយ និងទទួលការរំលោភផ្លូវភេទ ព្រមទាំងកុមារខ្លះពិការ រឺជួនកាលស្លាប់មុនអាយុពេញវ័យនេះហើយជាលទ្ធផល នៃពលកម្មរបស់ពួកគេ។ ឯអ្នកខ្លះទៀតចេះតែមានអារម្មណ៍ភ័យខ្លាចតក់ស្លុត ចំពោះ ជីវិតរបស់ពួកគេ។



មានកុមារពលកម្មជាច្រើនដែលពុំមានអ្នកណាបានដឹង និងឃើញដោយសារតែការងាររបស់គេជារបររកស៊ីលាក់កំបាំង ឬ ក៏ដោយសារតែសង្គមគ្រាន់តែមើល តែ ពុំបានយកចិត្តទុកដាក់។

អង្គការពលកម្មកុមារអន្តរជាតិគឺជាបណ្តាញខ្សែរយៈមួយដែលបានគិតគូរយ៉ាងច្រើនដល់កុមារពលកម្ម និងព្យាយាមប៉ាន់ស្មានមើលចំនួនកុមារពលកម្មដែលប្រទះឃើញក្នុងពិភពផែនដីនេះ។

-ប៉ុន្តែដើម្បីធ្វើដូច្នេះបានគឺត្រូវការពេលវេលាការស្រាវជ្រាវនេះទាមទារពេលវេលាអនុវត្តដោយប្រុងប្រយ័ត្នរកឱ្យឃើញប្រភេទផ្សេងៗគ្នាចំពោះពលកម្មប្រកបដោយគ្រោះថ្នាក់បំផុតឧទាហរណ៍ ៖ ដូចជាពេស្យាចារកុមារ កុមារយោធាកុមារបំរើការងារតាមផ្ទះ ទាំងអស់ នេះជាកិច្ចការដ៏លំបាកបំផុតសម្រាប់អ្នកស្រាវជ្រាវ។

- ទោះជាយ៉ាងណាក៏ដោយ ការធ្វើឱ្យមើលឃើញនូវពលកម្មកុមារ នឹងអាចជួយដល់សង្គមដើម្បីកំចាត់នូវអ្វីៗដែលអាក្រក់ផ្សេងៗចេញពីសង្គម។ ការធ្វើឱ្យមើលឃើញពលកម្មកុមារទាំងអស់នេះគឺមានចែងក្នុងសៀវភៅនេះ។ សមាសភាគសំខាន់បំផុតសម្រាប់ទ្រទ្រង់សកម្មភាពបញ្ឈប់ពលកម្មកុមារ គឺ ការអប់រំ និងការលុបបំបាត់ភាពក្រីក្រ ។

នៅក្នុងឆ្នាំ២០០០គ្រាន់តែកុមារពុំបានចូលរៀនមានដល់ទៅ ១៣%នៃចំនួនកុមារទាំងអស់ដែលស្ថិតក្នុងអាយុពី ១០ ទៅ ១៤ឆ្នាំ ដោយពួកគេត្រូវទៅធ្វើការផ្ទុយពីទៅរៀន។ ប៉ុន្តែទន្ទឹមនឹងនេះ រៀងរាល់ឆ្នាំតែងមានកុមារចូលសាលារៀនដូច្នេះពួកគេអាចកាត់បន្ថយការងារពលកម្មរបស់ពួកគេ។

ការសិក្សាគឺជាសិទ្ធរបស់កុមារគ្រប់រូប ប៉ុន្តែត្រូវប្រកបដោយគុណភាពល្អ ហើយអ្នកណាក៏អាចទទួលបានដោយឥតគិតថ្លៃ បើមិនដូច្នេះទេគឺមិនអាចសំរេចគោលដៅដែលចង់បានឡើយ ។

ម៉ូឌុលនេះ បានផ្តល់នូវហេតុការណ៍ និងតួលេខជាមូលដ្ឋានគ្រឹះខ្លះៗ ដែលអាចឱ្យយុវជនយល់ដឹងច្បាស់ថា ពួកគេជាប្រភពផ្តល់ព័ត៌មានពិត និងសំខាន់បំផុតស្តីពីពលកម្មកុមារ ។



**កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់ :**

គំនិតដែលតំរូវឱ្យអនុវត្តម៉ូឌុលនេះយ៉ាងឆាប់រហ័ស គឺជាគំនិតមួយដ៏ល្អ ។ ម៉ូឌុលនេះ ជាម៉ូឌុលផ្ដើមដំបូង គេបង្អស់ហើយមានរូបគំនូរផង ។ មានម៉ូឌុលពីរដែលអាចបណ្ដុះការស្រមៃឃើញអំពីកុមារពលកម្មក្នុងអារម្មណ៍យុវជន ពួកគេនឹងជួយផ្ដល់គំនិតជាមូលដ្ឋានគ្រឹះសម្រាប់ដំណើរការអនុវត្តម៉ូឌុលផ្សេងៗទៀត ។

ក្នុងដំណាក់កាលបន្ទទៀតគឺការស្រាវជ្រាវ និងព័ត៌មាន" យើងសូមឱ្យអ្នកអនុវត្តម៉ូឌុលនេះ (Research and information)" ជួយលើកទឹកចិត្តយុវជនឱ្យពួកគេស្វែងរកព័ត៌មានលំអិតអំពីកុមារពលកម្ម ។ ដូច្នេះមិនត្រូវប្រើសិទ្ធិបង្ខំពួកគេឱ្យឆ្លើយនិងមិនត្រូវធ្វើឱ្យពួកគេបាក់ទឹកចិត្តលែងចង់សិក្សាពីករណីទាំងនេះឡើយ ។ ម៉ូឌុលនេះ ទាក់ទងជាមួយនឹងស្ថិតិសំខាន់ៗ ដែលត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយដោយអង្គការផ្សេងៗ រដ្ឋាភិបាល និងប្រព័ន្ធ ផ្សព្វផ្សាយព័ត៌មាន ។

## ការរៀបចំ

ម៉ូឌុលនេះទាមទារឱ្យមានការរៀបចំតាមរបៀបរបស់វា ព្រោះថារាល់ព័ត៌មានដែលអ្នកប្រើប្រាស់មាននៅក្នុងឧបសម្ព័ន្ធ ។ ជាការហ្វឹកហាត់ យើងត្រូវជំរុញឱ្យមានការពិភាក្សាក្នុងក្រុម ។ រក្សាទុករាល់គំនិតរួមនៃក្រុមពិភាក្សាព្រមទាំងចំណាប់អារម្មណ៍របស់យុវជន ។ ការហ្វឹកហាត់ពិភាក្សានេះត្រូវបញ្ចូលព័ត៌មានចេញពីម៉ូឌុល ហើយណែនាំឱ្យពិភាក្សាជំរុញព័ត៌មាននោះ ។ ការប្រើប្រាស់លំហាត់ហ្វឹកហ្វឺននេះ គឺមានប្រយោជន៍សម្រាប់លើកគម្រោងឱ្យបានច្បាស់លាស់ និងសម្រាប់ឱ្យក្រុមពិភាក្សាយល់ថាគម្រោងនេះកើតចេញពីអ្វីមួយក្រៅពីរឿងធម្មតា ហើយញ៉ាំងឱ្យការអប់រំមានដំណើរការទៅមុខ ។





## កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់ :

ប្រសិនបើអ្នកអាចជួបប្រធានផ្នែកការិយាល័យអង្គការពលកម្មកុមារពិភពលោកនៅ Geneva ( សូមមើលសៀវភៅលំអិតអំពីទំនាក់ទំនង ) ហើយបើត្រូវប្រើប្រាស់កាសែតវីដេអូ សូមស្នើសុំថតចំលងកាសែតវីដេអូរយៈពេល១០នាទីដែលមានចំណងជើងថាប្រយុទ្ធនឹងពលកម្មកុមារដែលជាមូលហេតុរួម" Combating Child Labour cause" កាសែតវីដេអូនេះបានឆ្លុះបញ្ចាំងបង្ហាញ រឿងរ៉ាវកុមារពលកម្មដល់កុមារទាំងឡាយ ។ កាសែតនេះបង្ហាញព័ត៌មានជុំវិញព្រឹត្តិការណ៍ដែលអង្គការពលកម្មអន្តរជាតិទទួលបាន និងនិយាយអំពីកុមារពលកម្ម នៅ hazardous ផងដែរ ។ការប្រឹងប្រែងដើម្បីទទួលបានរូបភាពទាំងនេះគឺមានការលំបាកខ្លាំងណាស់ ។

អង្គការមួយចំនួនជុំវិញពិភពលោក បានថតខ្សែវីដេអូស្តីអំពីអាជីវកម្មកុមារប្រៀបបានទៅនឹងទាសភាព ឬ ទាសករនៃពលកម្ម ។ បើសិនជាអ្នកចង់ខ្ចីកាសែតបែបនេះត្រូវទាក់ទងការិយាល័យតំបន់នៃអង្គការទាំងនោះ ។ នៅបណ្តាប្រទេសខ្លះមជ្ឈមណ្ឌលសិទ្ធមនុស្សបានបង្កើតបណ្ណាល័យ និងបំរើសេវាកម្មឱ្យខ្ចីសម្រាប់ការងាររបៀបនេះ ។

អ្នកអាចចូលទៅមើលមជ្ឈមណ្ឌលណាដែលនៅជិតជាងគេនោះ អ្នកនឹងបានដឹងនូវអ្វីដែលត្រូវទាក់ទងនឹងប្រភពព័ត៌មានផ្សេងៗ ដែលអាចជួយអ្នកក្នុងការអនុវត្តការងារ ។ មិនតែប៉ុណ្ណោះ ស្ថាប័នរដ្ឋាភិបាលក៏មានបំរើសេវាព័ត៌មានដែលអាចឱ្យសាធារណជនមកពិគ្រោះយោបល់ ។ រាល់ប្រភពព័ត៌មានដែលគេយកចិត្តទុកដាក់បំផុតគឺសំដៅតែលើបញ្ហាកុមារពលកម្ម ។



## អ្វីដែលអ្នកត្រូវការ

ជាចាំបាច់អ្នកត្រូវការសំភារៈខ្លះៗសម្រាប់ចងក្រងមេរៀនដែលអាចជួយជំរុញឱ្យក្រុមពិភាក្សាលើបញ្ហាពលកម្មកុមារកាន់តែមានប្រសិទ្ធភាព :



- ហេតុការណ៍ពិត និងភាពមិនសមហេតុផលក្នុងឧបសម្ព័ន្ធ
- ក្តារខៀន ឬ ផ្ទាំងក្រដាស
- ក្រដាស ខ្មៅដៃ ឬ ប៊ិចសម្រាប់ឱ្យក្រុមពិភាក្សាសរសេរ
- ទូរទស្សន៍ និងកាសែតវីដេអូ ប្រសិនបើអ្នកត្រូវប្រើប្រាស់ជាចាំបាច់នូវឧបករណ៍វីដេអូ

- រូបថតកាតាឡុករបស់ " កម្មវិធីលុបបំបាត់ពលកម្មកុមារ " អន្តរជាតិ និងCD- Rom ដែលបញ្ចូលនូវការអប់រំជាច្រើនស្តីពីពលកម្មកុមារ
- សៀវភៅ ឬ ឯកសារបោះពុម្ពផ្សាយផ្សេងៗ ដែលអ្នកអាចខ្ចីត្រូវមានរូបភាពស្តីពីកុមារធ្វើពលកម្ម ។



## ការចាប់ផ្តើម

ត្រូវណែនាំឱ្យអង្គុយជារង្វង់ ពាក់កណ្តាលរង្វង់ រឺមានសណ្ឋានជារាងក្រចកសេះនៅជុំវិញអ្នក ។ ប្រសិនបើក្មេងៗអង្គុយនៅពីក្រោយតុ ត្រូវយកតុចេញព្រោះការរៀបតុរបៀបនេះជាលក្ខណៈអប់រំបុរាណ និងមិនត្រូវតាមក្បួនគរុកោសល្យទេ។ ត្រូវរើតុយកទៅដាក់មួយកន្លែង រួចហើយឱ្យពួកគេរៀបកៅអីអង្គុយជុំវិញអ្នក ឬពួកគេអាចអង្គុយផ្ទាល់ទៅនឹងឥដ្ឋ ជុំវិញអ្នកក៏បានដែរ ។ ម្យ៉ាងទៀត ដំណើរការរៀបចំយ៉ាងនេះអាចជួយជំរុញឱ្យមានការចាប់អារម្មណ៍យ៉ាងឆាប់ និងរំជួលចិត្តផងបន្ទាប់មកទៀតគឺជាដំណើរការពិភាក្សា ។ ការរៀបចំបន្ទប់ដូច្នេះ គឺសមស្របបំផុតព្រោះពួកគេអាចមើលមុខគ្នា ភ្នែកសំលឹងគ្នាទៅវិញទៅមកម្យ៉ាងទៀតងាយស្រួលក្នុងការផ្លាស់ប្តូរកន្លែងដោយពុំចាំបាច់ទាញតុកៅអីចុះឡើង ។

ការរៀបចំក្រុម



ត្រូវធ្វើយ៉ាងណាឱ្យក្រុមនីមួយៗអាចរៀបចំទីកន្លែងដោយខ្លួនឯង។ តាមបទពិសោធន៍នៅប្រទេសមួយចំនួន ជាធម្មតាក្រុមកុមារាតែងតែនៅផ្តុំគ្នាមួយក្រុមកុមារីផ្តុំគ្នាមួយក្រុមផ្សេងទៀត ទោះបីអ្នកពុំបានបែងចែកក្រុមទៅតាមភេទក៏ដោយកុមារដែលមានមិត្តជិតស្និតពួកគេតែងតែចង់នៅជិតគ្នា ។ ទោះជាយ៉ាងណាក៏ដោយកម្មវិធីនេះចង់បានការប្រកួតប្រជែង ដូច្នេះត្រូវរៀបចំសម្រួលយ៉ាងណាឱ្យអង្គុយឆ្លាស់គ្នា ឧទាហរណ៍ កុមារា កុមារី កុមារា កុមារីនៅជុំវិញអ្នក ។ ចូរប្រមើលមើលថាតើអ្នកពុំអាចបំបែកក្រុមដែលចង់នៅផ្តុំគ្នាឬយ៉ាងណា កុំធ្វើឱ្យពួកគេម្នាក់ៗមានអារម្មណ៍មិនល្អ និងបាត់បង់ការខំប្រឹងប្រែង។ ប៉ុន្តែផ្ទុយទៅវិញ ការធ្វើយ៉ាងនេះគឺ ដើម្បីឱ្យក្រុមនីមួយៗបង្កើនសន្ទុះទឹកចិត្តដ៏មោះមុត។

## សកម្មភាព១ : តើពលកម្មកុមារគឺជាអ្វី?

បង្រៀនមួយពេល ឬកន្លះដងពីរពេល



-មុននឹងចាប់ផ្តើមមេរៀនត្រូវសួរសំណួរងាយៗដូចជា :

តើអ្នកយល់ដឹងអ្វីខ្លះពីកុមារពលកម្ម? តើអ្នកយល់ឃើញយ៉ាងណាដែរ?

ជំរុញពួកគេម្នាក់ៗឱ្យប្រាប់អំពីអ្វី ដែលពួកគេបានដឹង និងអំពីអ្វីដែលពួកគេបានលឺបានសិក្សាតាមទូរទស្សន៍ឬកាសែត និងអំពីអ្វីដែលពួកគេធ្លាប់ឆ្លងកាត់ក្នុងបទពិសោធន៍ជាកុមារពលកម្មពីមុនមក ។ គោលបំណងរបស់អ្នក គឺចង់ឱ្យពួកគេបង្ហាញឱ្យឃើញនូវអ្វីៗដែលកើតឡើងថ្មីៗ ។ កត់ត្រានៅលើក្តារខៀន ឬផ្ទាំងក្រដាសនូវក្រដាសផ្សេងៗដែលពួកគេ ប្រាប់ ។

ប្រសិនបើយឺតយ៉ាវក្នុងការចាប់ផ្តើមដំបូង អ្នកអាចជំរុញឱ្យមានការពិភាក្សាដោយលើកឡើងនូវសំនួរបំផុសខ្លះៗ ដូចជា :

-តើកុមារទាំងនោះស្ថិតក្នុងអាយុប៉ុន្មាន? កាលណាយើងនាំគ្នានិយាយអំពីកុមារពលកម្ម?

- តើកុមារពលកម្មគឺជាកុមារា ឬកុមារី រឺក៏ទាំងពីរភេទ?
- តើការងារប្រភេទណាខ្លះដែលយើងលើកយកមកនិយាយ?
- តើកុមារពលកម្មស្ថិតនៅឯណា? តំបន់ណាខ្លះ? ប្រទេសណាខ្លះនៃពិភពលោក
- តើកុមារពលកម្មមានប្រាក់ខែឬទេ?
- តើពួកគេបានធ្វើកិច្ចសន្យាត្រឹមត្រូវ ឬទេ?
- តើពួកគេមានផ្ទះនៅ ឬទេ?
- តើពួកគេបានទៅសាលារៀន ឬទេ?

សំនួរទាំងនេះ គ្រាន់តែចង់ធ្វើឱ្យដំណើរការទៅមុខយ៉ាងរហ័ស ដើម្បីជួយពួកគេឱ្យត្រិះរិះតាមរយៈចំណេះដឹងដែលគេមាន និងចង់មើលថាតើពួកគេគិតយ៉ាងដូចម្តេចអំពីករណីនេះពីមុនមក ហើយពួកគេយកចិត្តទុកដាក់ដល់កំរិតណា។

ប្រសិនបើអ្នក ធ្វើការណែនាំបង្ហាញតាមរយៈកាសែតវីដេអូ គឺត្រូវបង្ហាញបន្ទាប់ពីការពិភាក្សាចប់។ នៅពេលបញ្ចាំងវីដេអូអ្នកត្រូវឈរនៅជ្រុងម្ខាងនៃបន្ទប់ ហើយសំលឹងមើលតើពួកគេម្នាក់ៗមានប្រតិកម្មយ៉ាងណា?

ប្រសិនបើអ្នករស់នៅក្នុងប្រទេសដែលមានកុមារពលកម្ម ឬអ្នកធ្វើការជាមួយកុមារដែលមានបទពិសោធន៍ជាកុមារពលកម្មពីមុនមក ពេលនោះមេរៀននេះបង្ហាញនូវប្រតិកម្ម(ការបង្កហេតុ)ផ្សេងៗគ្នា។

នៅពេលដែលពួកគេបញ្ជាក់ប្រាប់អ្នកពីហេតុផលសមស្របខ្លះដែលទាក់ទងនឹងកុមារពលកម្មដូចជា ពួកគេកំពុងធ្វើអ្វីនៅក្នុងប្រទេសពួកគេ អ្នកត្រូវកត់ត្រាទុករាល់ចំនុចសំខាន់ៗនៃការពិភាក្សាតាមលទ្ធភាពដែលអាចធ្វើបាន។ វិធីនេះជួយធ្វើឱ្យពួកគេមានជំនឿទុកចិត្តចំពោះក្រុម ក្នុងពេលដែលគេរៀបរាប់រាល់បទពិសោធន៍ទាំងឡាយដែលពួកគេធ្លាប់ឆ្លងកាត់។ ទោះបីយ៉ាងណាក៏ដោយ ពេលខ្លះការពិភាក្សាអាចចាកឆ្ងាយពីប្រធានបទដែលចង់បាន ដូច្នេះត្រូវចាប់ផ្តើមសួរសំនួរមួយថា "តើអ្នកបានដឹងអ្វីខ្លះអំពីកុមារពលកម្មនៅក្នុងប្រទេសផ្សេងៗជុំវិញពិភពលោក"។ ឬក៏សួរសំនួរពីខាងលើដដែលទៀតដើម្បីកន្ត្រាក់អារម្មណ៏ពួកគេ។ ឥឡូវនេះ ពួកគេនឹងប្តូរប្រធានបទមកគិតថា តើត្រូវជួយសង្គ្រោះកុមារពលកម្មដោយវិធីណា? ពួកគេនឹងត្រិះរិះនូវអ្វីៗដែលពុំធ្លាប់បានគិតពីមុនមកមានន័យថា កុមារឯទៀតជុំវិញពិភពលោកប្រហែលជានឹងជួបស្ថានភាពដ៏អាក្រក់ ។



**កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់:**

ការពិភាក្សាដំបូងនេះមិនចាំបាច់ធ្វើឱ្យជិតដល់ពេកនោះទេ។ នៅមានពេលសម្រាប់ពិភាក្សាវែកញែកអំពីកុមារពលកម្មនៅកម្មវិធីពេលក្រោយ និង នៅពេលអ្នកទាក់ទងជាមួយមេរៀនលើកក្រោយទៀត។អ្នកមិនចាំបាច់ប្រើប្រាស់គ្រប់សំនួរដែលមាននៅក្នុងមេរៀននេះឡើយ។ វាពុំមានបញ្ហាអ្វីទេ ប្រសិនប្រើសំនួរលើសទៅហើយ។ ប៉ុន្តែជាការល្អ គឺគ្រាន់តែប្រើសំនួរណាដែលគិតថាទាក់ទងចំពោះស្ថានភាពរបស់យើងផ្ទាល់។ ហើយក៏ពុំមែនជាការប្រកួតប្រជែងរកអ្នកដែលដឹងរឿងច្រើននោះឡើយ។

នៅក្នុងឧបសម្ព័ន្ធនៃមេរៀននេះ គេបានបញ្ចូលបន្ថែមនូវស្ថិតិព័ត៌មានទូទៅស្តីពីពលកម្មកុមារ ។ យើងគ្រាន់តែថតចម្លងស្ថិតិនោះ រួចយកទៅបង្ហាញក្រុមពិភាក្សា ដើម្បីប្រើប្រាស់វាក្នុងពេលពិភាក្សាទូទៅ ។ ឧទាហរណ៍ ប្រសិនបើការពិភាក្សាជិតឈានចូលដល់ត្រង់កន្លែងចប់ ហើយយើងត្រូវបង្វែទិសដោយសួរសំនួរថា : តើក្មេងដែលបម្រើការងារតាមផ្ទះមានអាយុប៉ុន្មានដែរ?

ពួកគេប្រហែលជាអាចស្មានត្រូវ ប៉ុន្តែបន្ទាប់មកយើងត្រូវដឹកនាំក្រុមឱ្យពិភាក្សាត្រង់ចំនុចនេះដោយយោងតាមតួរលេខនៃស្ថិតិ ។ ឧទាហរណ៍ តើប្រទេសឥណ្ឌូនេស៊ីមានកុមារធ្វើការតាមផ្ទះប៉ុន្មាននាក់ ? តើពួកគេធ្វើការប៉ុន្មានម៉ោង? តើពួកគេរងការឈឺចាប់ដោយការរំលោភយ៉ាងណាខ្លះ? យើងត្រូវប្រើប្រាស់តារាងស្ថិតិទាំងនេះដោយយកចិត្តទុកដាក់ មិនមែនគ្រាន់តែអានៗប៉ុណ្ណោះទេ ។ យើងប្រើប្រាស់ស្ថិតិនេះដើម្បីធ្វើឱ្យការពិភាក្សាតាមក្រុមមានការអភិវឌ្ឍន៍រីកចំរើនឡើង ។

អ្នកមិនគប្បីខំប្រឹងប្រើប្រាស់គ្រប់ស្ថិតិទាំងអស់ដែលមាននោះទេ ។ តារាងស្ថិតិយ៉ាងវែងត្រូវបានផ្តល់ឱ្យពួកអ្នកនៅទីនេះ ប៉ុន្តែស្ថិតិទាំងនេះសម្រាប់ឱ្យជ្រើសរើស បើពុំនោះទេអ្នកធ្វើឱ្យក្រុមច្របូកច្របល់ដោយពួកគេពុំអាចដោះស្រាយរាល់បញ្ហាតាមរយៈព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់នោះបានឡើយ ។

អ្នកមិនត្រូវធ្វើឱ្យបាត់ព័ត៌មានស្ថិតិទាំងនោះ ចាប់តាំងពីពេលដំបូងនៃដំណោះស្រាយឡើយ ។ ដូច្នេះ អ្នកត្រូវរក្សាទុកព័ត៌មាននោះជាពត៌មានធម្មតា ហើយរក្សាវាទុកតែចំនួនតិចតួចបានហើយសម្រាប់ដោះស្រាយ ។

## សកម្មភាព២ : មូលហេតុ និងផលវិបាកនៃកុមារពលកម្ម

៣០-៣៥ នាទី



ក្រោយពីបានធ្វើការពិភាក្សាដើមដំបូង និងផ្អែកលើអារម្មណ៍ ព្រមទាំងទំនោរចិត្តរបស់ក្រុម ចូរអ្នកធ្វើការសម្រេចចិត្តថា តើអ្នកអាចជំរុញការពិភាក្សាឱ្យទៅដល់បញ្ហាច្បាស់លាស់ជាងនេះនៅក្នុងតំបន់ដែលមានកុមារពលកម្មបានដែរ ឬ ក៏មិនអាច ។

ត្រូវចងចាំថាមិនត្រូវដាក់បញ្ហោសម្រាប់ការពិភាក្សាឱ្យច្រើនហួសហេតុពេកនោះទេ។ អ្នកត្រូវវិភាគរាល់ស្ថានភាព និងពាក្យសម្ដីទាំងឡាយរបស់ពួកគេ អ្នកត្រូវប្រាប់ពួកគេនៅពេលដែលការពិភាក្សាជិតចាកឆ្ងាយពីគោលដៅរបស់កម្មវិធី។ អ្នកអាចឱ្យការពិភាក្សាចាកឆ្ងាយពីគោលដៅបាន ប្រសិនបើជាករណីចាំបាច់។ នេះគឺជាប្រធានបទពិភាក្សា ដែលបណ្ដាលឱ្យវិលត្រឡប់ក្រោយទៅរកដំណាក់កាលផ្សេងៗគ្នានៃគំរោងអត្ថបទ។

ប្រធានបទសម្រាប់ពិភាក្សា

## តើកុមារពលកម្មកើតមានឡើងដោយសារអ្វី ?



សំនួរនេះ អ្នកអាចណែនាំឱ្យពួកគេពិភាក្សាតាមក្រុមលើករណីកុមារពលកម្មទាំងមូល ។ ពាក្យគន្លឹះសម្រាប់ប្រើក្នុងការពិភាក្សាគឺ " ហេតុអ្វី " ដែលអាចឱ្យពួកគេចាប់អារម្មណ៍ ជាពិសេសប្រសិនបើអ្នករស់នៅក្នុងប្រទេសដែលមានកុមារពលកម្មមិនមានចំនួនច្រើន។ ប្រសិនបើអ្នករស់នៅក្នុងប្រទេសដែលមានកុមារពលកម្មច្រើននោះ អ្នកកាន់តែចង់ស្ដាប់អ្វីដែលពួកគេប្រាប់អំពីមូលហេតុដែលនាំឱ្យគេគិត។ នេះជារឿងធម្មតាដែលកុមារខ្លះនៅក្នុងក្រុមរបស់អ្នកធ្វើការងារនេះ ព្រោះយើងរស់នៅលើផែនដីជាមួយគ្នា ។

នេះគឺជាចំនុចចាប់ផ្ដើមនៃពិភាក្សា ។ សួរថា :" តើមានអ្នកណាខ្លះនៅក្នុងក្រុមដែលធ្វើការងារពលកម្មនេះ ? ដេញដោលសួរឱ្យឃើញអ្វីខ្លះដែលពួកគេធ្វើ។ ពួកគេធ្វើការប៉ុន្មានម៉ោង? តើអ្នកណាខ្លះធ្វើការងារតាមផ្ទះ ? តើពួកគេឱ្យប្រាក់ខែប៉ុន្មាន? តើពួកគេមានអារម្មណ៍យ៉ាងដូចម្ដេចចំពោះការងារ? ។

នៅពេលដំបូងបង្អស់ហេតុអ្វីបានជាពួកគេមកធ្វើការ?តើហេតុអ្វីដែលបង្ខំឱ្យពួកគេរកការងារធ្វើ?

តើគំនិតប្រហាក់ប្រហែលគ្នាដែលយល់ឃើញថា កុមារដែលធ្វើការលំបាកលំបិនត្រូវតែឱ្យឈ្មោះថា"កុមារពលកម្ម" ឬ "ចុះរឿងផ្សេងពីនេះគេហៅអ្វីដែរ?

## ហេតុអ្វីបានជាគេចូលចិត្តយកកុមារទៅធ្វើការឱ្យគេ?

កុមារពលកម្មតែងកើតមានដោយសារអ្នកជួលខ្លះចូលចិត្តជួលកុមារជាងមនុស្សពេញវ័យ ។

ចូរសួរតាមក្រុមថា តើហេតុអ្វីបានជាពួកគេគិតដូច្នេះ? ហេតុអ្វីបានជាមនុស្សធំពេញកម្លាំងជំរុញទឹកចិត្តកុមារឱ្យធ្វើការដើម្បីពួកគេ? តើមូលហេតុអ្វីដែលបណ្ដាលឱ្យពួកគេជួលកុមារ?

ចូរសួរតាមក្រុមថា តើអ្នកជួលទាំងនោះបានគិតថាគ្រោះថ្នាក់អាចមានចំពោះកុមារឬទេ? តើពួកគេយល់ថាកុមារ គឺគ្មានរឿងអ្វីក្រៅពីធ្វើការមែនទេ? តើពួកគេជឿថា កុមារត្រូវទទួលការអប់រំដោយឥតគិតថ្លៃឬទេ? តើពួកគេមានគិតថាអ្វីដែលពួកគេធ្វើនឹងធ្វើឱ្យមានគ្រោះថ្នាក់ឬទេ? សំនួរខ្លះដែលលើកយកមកពិភាក្សាធ្វើឱ្យគេចាប់អារម្មណ៍ និងសំនួរខ្លះទៀតជំរុញការពិភាក្សាឱ្យកាន់តែប្រសើរឡើង។ ជាឧទាហរណ៍ អ្នកខ្លះអាចធ្លាប់ធ្វើជាកុមារពលកម្ម ដូច្នេះពួកគេមិនយល់ស្របថាអាចមានគ្រោះថ្នាក់ចំពោះកុមារឡើយ។ រឿងនេះបង្ហាញឱ្យឃើញនូវបញ្ហាទំនៀមទំលាប់ និងវប្បធម៌ទៅវិញ។ អញ្ចឹងមែនហើយ យើងចៀសមិនរួចរឿងខុស និងត្រូវដូចដែលអ្នកទស្សនៈវិជ្ជាបានវែកញែកថាខុស និងត្រូវគឺគេចមិនរួច ។

អ្នកជួលខ្លះមិនខ្វល់ឡើយ គោលបំណងតែមួយក្នុងជីវិតគឺធ្វើយ៉ាងណាឱ្យតែបានប្រាក់ច្រើន និងមិនគិតពីផលវិបាកឡើយ ។ ហេតុអ្វីបានជាពួកគេគិតតែមួយមុខអញ្ចឹង?

## តើពលកម្មកុមារគឺជារឿងមួយដែលអាក្រក់ឬ ?

សមាជិកក្រុមខ្លះអាចគិតថា កុមារពលកម្មពុំមែនជារឿងដែលអាក្រក់ឡើយ។ មានអ្នកខ្លះតវ៉ាថាវាកាន់តែអាក្រក់ទៅទៀតបើកុមារមិនធ្វើការ ព្រោះពួកគេនឹងគ្រួសាររបស់គេនឹងស្លាប់ដោយអត់ឃ្លាន។ សូមឱ្យក្រុមពិភាក្សារកមូលហេតុដែលត្រូវតែបញ្ឈប់កុមារពលកម្ម ហើយឱ្យពួកគេគិតថាកុមារគ្រប់គ្នាមានសិទ្ធ ដែលជាសិទ្ធមូលដ្ឋានគ្រឹះសម្រាប់កុមារភាពគ្រប់កាលៈទេសៈរបស់ពួកគេដូចជាសិទ្ធក្នុងការលេង សិទ្ធក្នុងការទៅរៀន និងទទួលការស្រលាញ់ រីករាយពីគ្រួសាររបស់ពួកគេ។

## ពលកម្មកុមារធ្វើឱ្យកុមារមានគ្រោះថ្នាក់ដូចម្ដេច?

ពេលនេះ ជាឱកាសពិភាក្សានៅក្នុងក្រុមអំពីហេតុដែលនាំឱ្យពលកម្មកុមារ(ពិសេសការងារពលកម្មផ្សងព្រេង) ធ្វើឱ្យកុមារគ្រោះថ្នាក់។

មិនជាបញ្ហាអ្វីទេ ទោះបីក្នុងក្រុមមានក្មេងៗដែលធ្វើការ ឬមិនធ្វើការនោះ តែវាជាការសំខាន់ ដែលពួកគេយល់ដឹងច្បាស់លាស់អំពីគ្រោះថ្នាក់ដែលកើតឡើងពីការងារ ហើយពួកគេចាំបាច់ត្រូវការពារកុំឱ្យកើតឡើងនូវរឿងទាំងនេះចំពោះខ្លួនគេ។ នៅពេលខ្លះក្មេងៗជឿជាក់ថា ពួកគេទទួលបានជោគជ័យជានិច្ចជាពិសេស នៅក្នុងប្រទេសឧស្សាហកម្មពួកគេអាចគិតថា គ្មានអ្វីដែលធ្វើឱ្យពួកគេមានគ្រោះថ្នាក់ឡើយ ហើយបញ្ហាការងារមិនធ្ងន់ធ្ងរទេ។ ទោះបីយ៉ាងណាក៏ដោយ កុមារអាចក្លាយជាសត្រូវដ៏អាក្រក់នឹងខ្លួនឯង ។

ពួកគេពុំយល់អំពីរឿងរ៉ាវ ឬ ឥទ្ធិពលដ៏យូរអង្វែងនៃគ្រោះថ្នាក់ដែលកើតឡើងពីបញ្ហាពលកម្ម។



ត្រូវឱ្យធ្វើការបង្ហាញអំពីទំរង់ពលកម្មផ្សេងៗធ្ងន់ធ្ងរ ហើយធ្ងន់ធ្ងរ បំផុត ហើយពលកម្មទាំងនេះបានធ្វើឱ្យកុមារមានគ្រោះថ្នាក់យ៉ាងណាខ្លះ។ រួចហើយរួមគ្នាពិចារណាអំពីទ្រង់ទ្រាយការងារណា ដែលកុមារទាំងនោះធ្វើ ហើយសួរពួកគេថា តើក្នុងចំណោមប្រភេទការងារទាំងអស់នោះការងារណាខ្លះដែលសមស្រប និងប្រសើរបំផុតចំពោះកុមារ។ នៅពេលនេះ អ្នកត្រូវចាប់ផ្តើមការពិភាក្សាត្រូវត្រៀមសម្ភារៈដូចជា ហ្វឺតក្តារខៀន ឬផ្ទាំងក្រដាស ដើម្បីកត់ត្រានូវគំនិតដែលពួកគេលើកឡើងជុំវិញពលកម្មកុមារ។

**កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់**

អាស្រ័យតាមពេលវេលារបស់អ្នក អ្នកអាចបំបែកក្រុមឱ្យទៅជាក្រុមតូចៗ សម្រាប់ធ្វើការពិភាក្សាដើម្បីឱ្យបានស៊ីជំរៅ និងក្បោះក្បាយ ធ្វើដូចនេះ អ្នកអាចឱ្យក្រុមនីមួយៗពិភាក្សាមានការងារស្រួល ហើយបន្ទាប់មកត្រូវឱ្យពួកគេរាយការណ៍ដល់ក្រុមទាំងមូល។ តាមវិធីនេះគ្រប់ៗគ្នាមានការងារស្រួលក្នុងការទទួលលទ្ធផលពិភាក្សាផ្សេងៗ។ ពួកគេប្រគល់លទ្ធផលដល់ក្រុមក្នុងពេលតែមួយ។ មិនជាបញ្ហាអ្វីឡើយ ពួកគេនៅតែស្ថិតនៅក្នុងក្រុមទាំងមូល ដើម្បីបំពេញការងារនេះ។វាគ្រាន់តែជំរុញឱ្យមានការឆាប់រហ័ស និងភាពពេញលេញតែប៉ុណ្ណោះ ។

## អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ



-ត្រូវមើលឱ្យឃើញច្បាស់លាស់នូវចំណុចជាវិជ្ជមាននៅក្នុងរឿងទាំងអស់។ អ្វីៗដែលម្នាក់ៗនិយាយគឺ គឺសំខាន់សមនឹងទទួលដឹងឮ។

-ត្រូវជំរុញគ្រប់ៗគ្នាឱ្យតាមដានការពិភាក្សាឱ្យបានជាប់លាប់ហើយរក្សាទុកភ្នែកម្ខាងសម្រាប់តាមដានអ្នកណាដែលរួញរាក្នុងចិត្ត ឬ អ្នកដែលចូលរួមប្លែកពីគេ។ សួរនាំពួកគេឱ្យបញ្ចេញគំនិត និងការយល់ដឹងរបស់ពួកគេ។

-ប្រើប្រាស់ភាសាទន់ភ្លន់នៅក្នុងការពិភាក្សា។ ដើរមើលតាមក្រុម និងធ្វើការពន្យល់ឱ្យបានក្បោះក្បាយ ។

-ប្រើប្រាស់ហេតុការណ៍ និងព័ត៌មានទូទៅនៅក្នុងឧបសម្ព័ន្ធសម្រាប់ម៉ូឌុលនេះ ដើម្បីជួយការពិភាក្សា។



-កុំពន្យាពេលពិភាក្សាយូរពេក ព្យាយាមថ្លឹងថ្លែងឱ្យមានតុល្យភាពក្រុម។ ប្រសិនបើការចាប់អារម្មណ៍ធ្លាក់ចុះ ត្រូវប្រញាប់ជំរុញក្រុមពិភាក្សាឱ្យមានចំណាប់អារម្មណ៍ខ្ពស់ឡើងវិញ ។យើងមិនត្រូវឱ្យពួកគេបាត់បង់ការយកចិត្តទុកដាក់ និងមិនត្រូវឱ្យពួកគេធុញទ្រាន់ឡើយ ។ រក្សាការពិភាក្សាឱ្យមានរយៈពេលយូរតែប្រកបដោយការចាប់អារម្មណ៍យ៉ាងទូលំទូលាយ ហើយមិនមែនមានតែម្នាក់ ឬពីរនាក់ដែលយកចិត្តទុកដាក់ប៉ុណ្ណោះទេ ។ អ្នកត្រូវតែយកចិត្តទុកដាក់ងាកមករកចំនុចសំខាន់ៗដែលមាននៅក្នុងមេរៀននេះ។

-ត្រូវព្យាយាមបញ្ចុះបញ្ចូលពួកគេម្នាក់ៗឱ្យពិភាក្សាវែកញែកឱ្យបានល្អ។ ប្រសិនបើអ្នកណាម្នាក់បង្ហាញ ការចាប់អារម្មណ៍ក្នុងប្រធានបទណាមួយ ត្រូវលើកទឹកចិត្តអ្នកនោះឱ្យពិភាក្សាត្រង់ចំនុចនោះ។ មេរៀនទាំងនោះមានឥទ្ធិពលចំពោះក្មេងៗ ហើយធ្វើឱ្យពួកគេមានសេចក្តីទុកចិត្តលើសមត្ថភាពរបស់ខ្លួនដូច្នេះធ្វើអ្វីៗទាំងអស់ត្រូវពោរពេញដោយការជឿទុកចិត្ត និងសេចក្តីគោរព។

-ត្រូវអនុញ្ញាតឱ្យមានការនិយាយលេង ការសន្ទនា និយាយចំអន់ លេងកំប្លែងលេង និងការប្រលងប្រជែងបើអាចធ្វើទៅបាន ។

-កុំបង្ខំឱ្យពួកគេម្នាក់ៗស្ថិតនៅក្រោមសម្ពាធ ឬក្នុងស្ថានភាពដែលអាចធ្វើឱ្យអន្តរាយចំពោះសេចក្តីជឿទុកចិត្តខ្លួនឯង។

ប្រសិនបើអ្នកណាម្នាក់ពុំធ្លាប់បានចូលរួមក្នុងការពិភាក្សាណាមួយនោះទេពិតជាពុំអាចត្រៀមគំនិតសម្រាប់និយាយបានឡើយ ដូច្នេះត្រូវប្តូរឱ្យអ្នកផ្សេងទៀតនិយាយម្តងវិញ។ ម្នាក់ៗនឹងចំណាយពេលចូលរួមផ្ទាល់ឯអ្នកខ្លះ ទៀតត្រូវការពេលវេលាយូរទើបអាចយល់បាន ។

## ការពិភាក្សាបញ្ចប់

១០-១៥ នាទី

នៅពេលអ្នកសម្រេចចិត្តថា ត្រូវបញ្ចប់ការពិភាក្សាត្រូវឱ្យក្រុមរួមគ្នាធ្វើការបូកសរុបទូទៅ។ គឺជាការល្អម្យ៉ាងសម្រាប់មេរៀនដំបូងដែលអាចយកជាបទពិសោធន៍សម្រាប់ក្រុមតែក៏មានការពិបាកខ្លះៗដែរចំពោះអ្នកខ្លះ។ ពួកគេនឹងបានដឹងលឺនូវការពិតខ្លះដើម្បីដោះស្រាយ ហើយដែលជនពេញវ័យខ្លះពុំអាចទទួលយកបានពោលគឺសម្រាប់ក្មេងៗប៉ុណ្ណោះ ។

កុមារពលកម្មគឺជារឿងភ័យខ្លាចមួយនៅក្នុងការធ្វើអាជីវកម្ម ដែលងាយនឹងធ្វើឱ្យគេមានការឈឺចាប់ ហើយវាបណ្តាលឱ្យគេទទួលការប៉ះទង្គិចខ្លាំងក្លាដូចជា មានរបួសខួរក្បាលលូតលាស់យឺត ជួនកាលរហូតដល់ស្លាប់ ។ រឿងរ៉ាវទាំងនេះ បង្ហាញឱ្យឃើញការពិតដល់ពិភពលោកអំពីកុមាររាប់លាននាក់ដែលត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ ។




ឥឡូវនេះ ក្រុមទាំងអស់នឹងបានយល់ច្បាស់ថា កុមារពលកម្មគឺជាអ្វីទៅ? ហេតុអ្វីក៏វាកើតឡើង។ អ្នកពុំចាំបាច់រៀបរាប់ឱ្យគ្រប់ទិដ្ឋភាពឡើយ

ប៉ុន្តែមេរៀននេះ គឺគ្រាន់តែរៀបចំដើម្បីបើកមុខឱ្យមើលនូវអ្វីៗដែលកើតមាននៅជុំវិញបញ្ហាកុមារពលកម្ម ។

ការពិភាក្សាខ្លះពិតជាមានការស្មុគស្មាញ ជាពិសេសករណីកុមារវ័យជំទង់ដែលតែងតែមានបញ្ហាកើតឡើងរុំក្រសោបខ្លួនរបស់ពួកគេ។ ហេតុដូច្នេះហើយជាការសំខាន់ ត្រូវរៀបចំចាត់ចែងមេរៀនទាំងនេះឱ្យយកចិត្តទុកដាក់ដើម្បីងាយស្រួលដោះស្រាយ ។ មិនត្រូវបណ្តាលឱ្យពួកគេម្នាក់ៗបញ្ចប់ការពិភាក្សាដោយពុំបានណែនាំពួកគេឱ្យចូលរួមជាមួយសកម្មភាពផ្សេងៗបន្តទៀតនោះទេ ។ ប្រើប្រាស់វគ្គបញ្ចប់នេះ ដើម្បីឱ្យពួកគេអាចមានការចាប់អារម្មណ៍ដោយខ្លួនឯងទៅតាមវិធីអ្វីដែលគេចង់ធ្វើ ។

ពុំត្រូវឱ្យពួកគេដកថយឡើយ បើគេពុំចង់ដោះស្រាយករណីណាមួយនៃកុមារពលកម្មត្រូវប្តូរឱ្យពួកគេបែរមកប្រធានបទផ្សេងវិញ ដែលអាចឱ្យពួកគេចាប់អារម្មណ៍ឡើងវិញ។ សកម្មភាពនេះគឺជាដំណើរការធ្វើឱ្យមានការចាប់អារម្មណ៍ឡើងវិញ ហើយវាក៏ជួយអ្នកឱ្យយល់ដោយស៊ីជម្រៅថា តើអារម្មណ៍របស់ពួកគេកំពុងគិតអ្វី? តើអ្វីទៅជាអារម្មណ៍ពិតរបស់គេ និងជាលទ្ធផលនៃការពិភាក្សាដំបូងបង្អស់ អ្វីៗទាំងឡាយត្រូវធ្វើតាមសម្រួល ។ ពេលខ្លះមិនត្រូវបង្ខំពេកនោះទេ ប៉ុន្តែត្រូវឱ្យពួកគេចាប់អារម្មណ៍ ដោយខ្លួនឯង និងយល់ឃើញកន្លែងដែលត្រូវបញ្ចប់ ។

ការផ្តល់សេរីភាពនេះនឹងអាចឱ្យពួកគេមានសេចក្តីទុកចិត្ត និងការជឿជាក់ចំពោះអ្នក ។ ជាការសំខាន់ណាស់ ដែលពួកគេមានអារម្មណ៍ថាពួកគេអាចបង្ហាញពីអារម្មណ៍ផ្ទាល់របស់ពួកគេទៅកាន់ក្រុម និងរូបអ្នកដោយគ្មានការលាក់លៀម ឬខ្មាសអៀន ។

ពួកគេមានអារម្មណ៍ថារូបអ្នកកំពុងស្តាប់ ហើយធានារ៉ាប់រងចំពោះអ្វីដែលពួកគេបាននិយាយនៅពេលនោះ វានឹងចាប់ផ្តើមលើកឡើងជាវេទិកាមួយបើកចំហសិទ្ធក្នុងការកសាងកម្មវិធីរួមគ្នា ។យើងមើលរូបភាពនៃក្តីសង្ឃឹម និងសេចក្តីត្រូវការដែលនៅជុំវិញអ្វីៗគ្រប់យ៉ាងដែលអ្នកធ្វើ ហើយអ្នកអាចនិយាយបានថាក្រុមនេះពោរពេញទៅដោយក្តីសង្ឃឹម ។ កុមារពលកម្មនឹងត្រូវបានបញ្ឈប់នេះជាចំនុចសំខាន់ ។ នេះជាគោលបំណងនិយមមួយ ។

ឥឡូវនេះ ក្រុមទាំងអស់នឹងបានយល់ច្បាស់ថា កុមារពលកម្មគឺជាអ្វីទៅ? ហេតុអ្វីក៏វាកើតឡើង។ អ្នកពុំចាំបាច់រៀបរាប់ឱ្យគ្រប់ទិដ្ឋភាពឡើយ ប៉ុន្តែមេរៀននេះ គឺគ្រាន់តែរៀបចំដើម្បីបើកមុខឱ្យមើលនូវរឿងអ្វីៗដែលកើតមាននៅជុំវិញបញ្ហាកុមារពលកម្ម ។



## ការវាយតម្លៃ និងសកម្មភាពបន្ត



ពុំមានអាំងឌីកាទ័រពិតយកមកវាស់បានឡើយសម្រាប់មេរៀននេះ។ គោលបំណងចំបងគឺធ្វើគម្រោង និងដាក់វាឱ្យដំណើរការ ហើយសឹមជំរុញការយកចិត្តទុកដាក់ឱ្យកាន់តែទូលំទូលាយលើករណីកុមារពលកម្ម ។ អ្នកកំពុងតែមានការរំភើបមានមនោសញ្ចេតនា និងមានការយល់ដឹង។ ជាពិសេស អ្នកត្រូវដាក់គំរោងទាំងនេះឱ្យមានដំណើរការក្នុងបរិបទនេះ។

អាំងឌីកាទ័រសំខាន់បំផុតរបស់អ្នក ចំពោះកម្មវិធីនេះនឹងធ្វើឱ្យមានស្មារតីប្រុងប្រយ័ត្ន និងកាន់តែមានភាពស្និតស្នាលថែមទៀតជាមួយក្រុម ។

អ្នកវិភាគកាន់តែច្បាស់លាស់ថែមទៀត នៅពេលគិតដល់រឿងកុមារពលកម្មជាបន្តទៀត។ ការពិភាក្សាទាំងនេះ អាចធ្វើឱ្យមានការសប្បាយរីករាយផងដែរសម្រាប់យុវជន ។

មេរៀននេះអាចមានលក្ខណៈសាមញ្ញ ប៉ុន្តែមានអត្ថន័យជ្រាលជ្រៅ ដើម្បីបើកភ្នែក និង ត្រចៀកពួកគេឱ្យមើល និងស្តាប់អំពីបញ្ហាកុមារពលកម្ម ទោះជាមាន ឬមិនមែននៅក្នុងប្រទេសរបស់ពួកគេក៏ដោយ។ ពួកគេអាចមើលឃើញនូវខ្លឹមសារសំខាន់របស់មេរៀន និងចាប់ផ្តើមយល់ដឹងកាន់តែច្បាស់លាស់ថែមទៀតអំពីគ្រោះថ្នាក់ និងមហន្តរាយដែលជាលទ្ធផលរបស់ពលកម្មកុមារ។ ការយល់ដឹងនេះជាកត្តាមួយជំរុញពួកគេឱ្យកាន់តែចង់ដឹងចង់ធ្វើថែមទៀតទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

មេរៀននេះ នឹងចាប់ផ្តើមលាតត្រដាងអំពីការរំលោភ និងការកេងប្រវ័ញ្ចធ្វើអាជីវកម្មលើកុមារ ដែលកើតមានពាសពេញលើពិភពលោកក្នុងប្រទេសឧស្សាហកម្ម និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

មូលហេតុដែលបណ្តាលឱ្យពលកម្មកុមាររីកដុះដាលកាន់តែខ្លាំងឡើងក្នុងសតវត្សរនេះ នឹងនាពេលខាងមុខនេះ ដោយសារការរំលោភកើតឡើងដោយគ្មានអ្នកណាតវ៉ារើបម្រះ ហើយអស់សង្ឃឹមក្នុងការលាតត្រដាងការរំលោភនោះចេញមក។ នៅពេលដែលការរំលោភកើតមានឡើង រដ្ឋាភិបាល អាជ្ញាធរ និយោជក និងសង្គមទូទៅពុំបានប្រើប្រាស់សម្ពាធឱ្យខ្លាំងក្លាទៅលើបញ្ហានេះ ។

បញ្ហាទាំងនេះនឹងមានការផ្លាស់ប្តូរបន្តិចម្តងៗ ប្រជាជនក៏កាន់តែយល់ដឹងថែមទៀតព្រមទាំងធ្វើការប្រឆាំងតវ៉ា និងគាបសង្កត់បញ្ហាខាងលើនេះកាន់តែខ្លាំងឡើង។ កាលណាអ្នកបានបញ្ចប់សៀវភៅនេះភ្លាមដោយពេញចិត្តហើយនោះ សូមបន្តទៅសៀវភៅមួយថ្មីទៀត ។ យើងសូមជម្រាបថា សៀវភៅក្រោយមានឈ្មោះថា “Collage ” ដែលនឹងបង្ហាញការសប្បាយខ្លះនៅក្នុងខ្លឹមសាររបស់វា ។

## ឧបសម្ព័ន្ធ១

### ការពិត និងតួលេខ

- មានកុមារពលកម្ម ២៤៥.៥លាននាក់ ឋិតក្រោមអាយុ១៨ឆ្នាំនៅក្នុងពិភពលោក ។ ក្នុងចំណោមនេះជាង១៨៦លាននាក់ ឋិតក្នុងចន្លោះអាយុពី៥ ទៅ១៤ឆ្នាំ ហើយជាង៥៩លាននាក់មានអាយុពី ១៥ ទៅ ១៧ឆ្នាំ។
- ប្រហែល ១៧០លាន នាក់នៃកុមារពលកម្ម កំពុងធ្វើការនៅក្នុងសភាពផ្សងព្រេង។ ក្នុងចំណោមជាង ១១១លាននាក់ មានកុមារអាយុពី៥ ទៅ១៤ឆ្នាំ ហើយជាង៥៩លាននាក់ អាយុពី១៥ទៅ ១៧ឆ្នាំ។
- ប្រហែល ១៧៩ លាននាក់កំពុងធ្វើការ ហើយស្ថិតក្នុងស្ថានភាពអាក្រក់ និងពិបាកបំផុត ។
- ថែមលើសពីនេះទៀត តាមការស្ទាបស្ទង់ជាង ៨លាន នាក់នៃកុមារទាំងនេះ ស្ថិតក្នុងលក្ខខណ្ឌអាក្រក់សម្រាប់កុមារពលកម្ម។ ក្នុងនេះជិត៦លាន នាក់ ស្ថិតក្នុងការបង្ខិតបង្ខំ ហើយ០.៣លាននាក់ស្ថិតក្នុងការប្រើប្រាស់ក្នុងជម្លោះប្រដាប់អាវុធ (ធ្វើជាទាហាន)
- ជិត ២លាន នាក់ស្ថិតក្នុងលក្ខណៈជាពេស្យាចារ និងការថតបង្ហាញរូបភាពអាសអាភាស និងជាងកន្លះលាន នាក់ ទៀតស្ថិតក្នុងសកម្មភាពខុសច្បាប់។
- ប្រហែល ១.២លាន នាក់ត្រូវរងគ្រោះដោយសារជួញដូរ
- តាមការស្ទាបស្ទង់កុមារជិត ៣៥២ លាននាក់ ស្ថិតក្នុងអាយុពី ៥ ទៅ១៧ ហើយរកស៊ីចិញ្ចឹមជីវិតដោយមុខរបរធម្មតាដូចគេឯង។
- កុមារប្រហែល ២១១លាននាក់ ស្ថិតក្នុងលក្ខណៈជាអ្នករកស៊ីមុខរបរងាយៗ ហើយមានអាយុពី ៥ ទៅ១៤ឆ្នាំ។ ជិត ១៤១លាននាក់ មានអាយុពី ១៥ ទៅ ១៧ឆ្នាំ។
- ជាមធ្យមក្នុងកុមារម្នាក់ៗគិតក្នុងអាយុពី ៥ .៦ ឆ្នាំ ដល់១៧ឆ្នាំអាចចាត់ទុកជាកុមារពលកម្ម។
- ប្រហែលជា ៦០%នៃចំនួនកុមារ ២១១លាននាក់ (១២៧លាននាក់) ជាកុមារធ្វើការនៅអាស៊ីប៉ាស៊ីភិច
- ជិត ២៣ % (ប្រហែល៤៨លាននាក់ ) រស់នៅ Sub Saharan Africa

- ជាង ៦%( ប្រហែល១៣.៤លាននាក់) រស់នៅអាហ្វ្រិកខាងជើង និងភាគកណ្តាលខាងកើត
- ជាង ៨%( ប្រហែល១៧.៤លាននាក់) រស់នៅអាមេរិកឡាទីន និងការីប៊ីន ( Caribbcan) ។
- Sub Sagaran ទ្វីបអាហ្វ្រិកមានចំនួនកុមារធ្វើការខ្ពស់បំផុត ។
- កុមារភាគច្រើនធ្វើការនៅជនបទប្រកបរបរកសិកម្ម
- នៅក្នុងទ្វីបអាហ្វ្រិក កុមារអាយុពី ៨ឆ្នាំ ដល់៩ឆ្នាំ ចុះធ្វើការក្នុងដីជម្រៅ៣០ម៉ែត្រ ហើយធ្វើការ ៧ ទៅ៨ម៉ោងក្នុងមួយថ្ងៃនៅក្នុងអណ្តូងរ៉ែជីកត្បូង ដែលស្ថិតក្នុងកន្លែងចង្អៀតគ្មានខ្យល់ ឬ ពន្លឺគ្រប់គ្រាន់ និងមានដីបាក់សង្កត់ជាញឹកញាប់ ។
- នៅអណ្តូងជីកមាសប្រទេស ប៉េរូ កុមារអាយុ៦ឆ្នាំ ត្រូវធ្វើការយ៉ាងយូរ ដោយគ្មានការទប់ទល់នឹងលក្ខខណ្ឌធម្មជាតិជម្ងឺឈឺថ្កាត់អ្វីឡើយ ហើយពួកគេក៏មានគ្រោះថ្នាក់ដូចកុមារដទៃទៀតដែរ ។ នឹងពួកគេអាចមានជម្ងឺរលាកផ្លូវដង្ហើមទៀតផង ។
- កុមារពលកម្មធ្វើការលំបាកហើយច្រើនម៉ោង
- កុមារក្នុងស្រុកទម្លាប់ធ្វើការរួមគ្នាជាទ្រង់ទ្រាយកុមារពលកម្ម ។ ជាទូទៅក្នុងការរស់នៅ គេកំនត់ថាក្មេងស្រីៗត្រូវធ្វើការងារនៅតាមផ្ទះ ។ នេះជាផ្នែកមួយនៃការអប់រំរបស់ពួកគេ ។
- គ្រួសារភាគច្រើននៅទីក្រុងច្រើនតែងជ្រើសរើសយកកុមារមកពីជនបទតាមរយៈគ្រួសារ មិត្តភក្តិ និងអ្នកស្គាល់គ្នា ។ ភាគច្រើនពួកគេជាក្មេងកំព្រា ឬឪពុកម្តាយទីទ័លក្រ ឬមានតែម្តាយ ឬមានតែឪពុក ។
- ក្មេងដែលត្រូវគេបោះបង់ចោល ឬក្មេងដែលកំព្រា ត្រូវតែរកស៊ីចិញ្ចឹមគ្រួសារ ។ ស្ថានភាពនេះជំរុញឱ្យពួកគេក្លាយជាទាសករ ។ ក្មេងៗទាំងនោះរៀបរាប់ថា ពួកគេធ្វើអ្វីៗគ្រប់យ៉ាងដើម្បីបានហូបគ្រប់គ្រាន់ ប៉ុន្តែជួនកាលបានហូបតែបន្តិចបន្តួចដោយពុំមានប្រាក់គ្រប់គ្រាន់ ។ ពួកគេដេកនៅលើឥដ្ឋ ហើយទ្រាំទ្រជាមួយនឹងការរំលោភផ្លូវភេទ ឬរាងកាយដោយរស់នៅដាច់ឆ្ងាយពីគ្រួសារ ពួកគេពុំបានចូលរៀន ឬលេងជាមួយក្មេងៗដទៃទៀតដែលមានអាយុប្រហាក់ប្រហែលគ្នា ។
- កុមារភាគច្រើនមានអាយុនៅចន្លោះ ១២ឆ្នាំ និង ១៧ឆ្នាំ ប៉ុន្តែតាមការអង្កេត គេឃើញថាកុមារទាំងនោះខ្លះស្ថិតក្នុងអាយុ ៥ ឬ ៦ឆ្នាំ ។
- ម៉ោងធ្វើការរបស់កុមារកម្មករក្នុងស្រុកមានរយៈពេលយូ ១៥ ឬ ១៦ ម៉ោងដោយពុំមានការតវ៉ា ។
- កុមារមួយចំនួនដែលមានអាយុក្រោម ១៨ឆ្នាំ ត្រូវបង្ខិតបង្ខំឱ្យចូលធ្វើទាហាន ឬ ក៏ទៅធ្វើជាកម្មករអ្នកធ្វើសសៃ អ្នកធ្វើម្ហូប និងទាសករផ្លូវភេទ ។ គ្រាន់តែក្នុងចំនួនប្រហែល៣០០.០០០នាក់ មាន ១២០.០០០ នាក់នៅអាហ្វ្រិក ។ កុមារទាំងនោះស្ថិតក្នុងអាយុប្រហែលជា ៨ឆ្នាំ ។

- ក្មេងៗធ្វើការនៅជនបទច្រើនជាងនៅទីក្រុង ទោះបីស្ថានភាពនេះហាក់ដូចជាមានការផ្លាស់ប្តូរនៅបណ្តាប្រទេសនៅអាហ្វ្រិក ដោយសារការរីកចំរើននៃនគរូបនីយកម្មក៏ដោយ ។
- ក្មេងៗធ្វើការភាគច្រើននៅជនបទ ពុំបានផ្តល់ប្រាក់កំរៃឱ្យគ្រួសារឡើយ ។
- ជាធម្មតាពួកគេទទួលបានប្រាក់កម្រៃទាបពេក ។ ប្រាក់ឈ្នួលរបស់គេអាស្រ័យទៅលើអាយុរបស់ពួកគេ និងភេទក្នុងនោះក្មេងស្រីទទួលបានប្រាក់ឈ្នួលតិចជាងក្មេងប្រុស ។
- ក្មេងភាគច្រើនធ្វើការនៅពេលល្ងាច ឬពេលយប់ ។ ក្មេងស្រីៗ ដែលធ្វើការតាមផ្ទះសម្បែងត្រូវនៅផ្ទះជាមួយនឹងម្ចាស់ផ្ទះ ហើយអាចប្រឈមមុខជាមួយការរំលោភផ្លូវភេទទៀតផង ។
- ពេលខ្លះកុមារទាំងនោះត្រូវតែរកស៊ីលក់ដូរដើម្បីបានប្រាក់កាក់ខ្លះ ព្រោះពួកគេមិនចង់ស្លាប់ឡើយ ។
- ជួនកាលគេទិញក្មេងៗយកមកប្រើក្នុងលក្ខណៈ " ម៉ៅផ្តាច់មុខ " ដោយឱ្យកម្រៃខ្លះទៅគ្រួសាររបស់ពួកគេ រួចហើយគេយកក្មេងៗទាំងនោះទៅបប្រើក្នុងការងារស្រែចំការខ្លះយកទៅឱ្យរកស៊ីជួញដូរក្នុងស្រុកបម្រើសេវាកម្មផ្លូវភេទ យកទៅធ្វើការនៅរោងចក្រផលិតសម្ភារៈវាយនភ័ណ្ឌកន្លែងវាយបំបែកថ្ម ។ប្រភេទកុមារពលកម្មបែបនេះ ត្រូវបានគេរាយការណ៍ពីអាស៊ីខាងត្បូងខាងកើត និងអាហ្វ្រិកខាងលិចទោះមានការប្រកែកតវ៉ាជាផ្លូវការក៏ដោយ ។
- ចំណងរួមមួយដែលជាប់ជំពាក់ខ្លាំងបំផុតគឺចំណងគ្រួសារ ហេតុនេះហើយកុមារត្រូវតែធ្វើការដើម្បីជួយដោះស្រាយឪពុកម្តាយឱ្យរួចផុតពីការខ្ចីបុល ឬ ក៏ជាកាតព្វកិច្ចផ្សេងៗទៀតពាក់ព័ន្ធនឹងគ្រួសារ ។ ម្ចាស់ដី ឬ ម្ចាស់បំណុលតែងតែប្រើប្រាស់ស្ថានភាពពិបាករបស់កូនបំណុល ដើម្បីឱ្យកូនបំណុលសងបំណុលតាមរយៈការងារ ។
- គ្រួសារមួយអាចនៅតែបន្តដោះស្រាយបំណុលរហូតដល់កូនដល់ចៅ ។
- ជាញឹកញាប់ មានកិច្ចសន្យាបំណុលចំពោះគ្រួសារ ដែលក្រីក្រដែលត្រូវបង្ខំចិត្តពួកគេឱ្យបញ្ជូនកូនទៅធ្វើការ ដើម្បីរកលុយមកសងបំណុល ដោយយល់ឃើញថាជាការប្រសើរជាងប្រគល់កូនរបស់ពួកគេឱ្យក្លាយជាអ្នកបំរើដោយពុំចាំបាច់សងប្រាក់ ហើយរស់នៅក្នុងផ្ទះជាមួយអ្នកមានទ្រព្យសម្បត្តិ ឃ្លាតឆ្ងាយពីឪពុកម្តាយរបស់ពួកគេ ។
- ពួកក្មេងៗច្រើនតែចាញ់ល្បិច ដោយមធ្យោបាយបោកប្រាស់ផ្សេងៗតាមរយៈការជួញដូរផ្លូវភេទជាពេស្យា ចោរ និងការថតរូបអាសអាភាស ។ល ។
- ការជួញដូរផ្លូវភេទគឺជាអំពើឃោឃៅព្រៃផ្សៃមួយមកលើកុមារ ។ កុមាររងគ្រោះគឺជាកម្មវត្ថុដែលឋិតក្រោមរូបភាពពលកម្មកុមារ ។កុមារទទួលនូវការឈឺចុកចាប់ចំពោះរាងកាយខ្លាំងក្លាបំផុត ។ អំពើខាងលើនេះ មិនអាចឱ្យកុមារទទួលបាននូវអនាគតដ៏ល្អបានឡើយក្នុងមួយជីវិតរបស់ពួកគេ ។

- កុមារដែលស្ថិតក្នុងការជួញដូរផ្លូវភេទ ត្រូវប្រឈមមុខនឹងការឆាប់មានផ្ទៃពោះ ការស្លាប់នៅពេលសម្រាលកូន ជំងឺកាមរោគដូចជា HIV/AIDS ទៀតផង ។ ករណីសិក្សាមួយចំនួនតាមរយៈសាក្សីកុមាររងគ្រោះបានឱ្យដឹងថា កុមាររងគ្រោះទាំងនោះពុំអាចត្រឡប់មកដូចក្មេងដ៏ទៃទៀតឡើយ ។ ភាគច្រើនពួកគេត្រូវស្លាប់មុនអាយុពេញវ័យទៅទៀតផង ។
- ការជួញដូរផ្លូវភេទលើកុមារត្រូវបានគេរាយការណ៍ថាកំពុងមានការកើនឡើង ។
- ប្រទេសខ្លះ (អឺរ៉ុបប៉ែកខាងកើត) ឆ្លុះបញ្ចាំងឱ្យឃើញនូវភាពរីកដុះដាលកាន់តែខ្លាំងឡើងនៃអំពើជួរស្ត្រី និង កុមារ ។
- ជារៀងរាល់ឆ្នាំកុមារម្នាក់ដែលបានចូលរៀនសាលារៀនអាចបញ្ជាក់ថា បានកាត់បន្ថយឱកាសដែលធ្វើឱ្យពួកគេទៅធ្វើការផងដែរ ។

# ឧបសម្ព័ន្ធ២

## មូលហេតុ និងផលវិបាករបស់កុមារពលកម្ម

### កង្វះខាតការអប់រំ

មានមូលហេតុជាច្រើនដែលធ្វើឱ្យកុមារត្រូវធ្វើការពុំបានចូលរៀនសាលារៀន ។ មូលដ្ឋានគ្រឹះនៃការអប់រំក្នុងបណ្តាប្រទេសមួយចំនួនធំគឺត្រូវបង់ថ្លៃ ហើយក្មេងៗទាំងនោះពុំមានលទ្ធភាពដើម្បី ចូលរៀនគ្រប់ៗគ្នាឡើយ ។ មានទីតាំងភូមិសាស្ត្រសាលារៀនក៏មានពិត តែគុណភាពអប់រំនៅខ្សោយពុំអាចបំពេញតម្រូវការបាន ។

នៅក្នុងស្ថានភាពពុំអាចទៅរៀន ឬ ឪពុកម្តាយពុំយល់ពីតម្លៃនៃការអប់រំកុមារទាំងនោះត្រូវបញ្ជូនទៅធ្វើការជំនួសការទៅរៀន ។ ចំនុចសំខាន់ដែលប៉ះពាល់លើកុមារគឺភាពទីទាល់ក្រការពាក់ព័ន្ធជាមួយវប្បធម៌ និងអ្វីដែលមិនល្អក្នុងសង្គមព្រមទាំងការបោះបង់ពួកគេចោល ។បញ្ហាខាងលើនេះបណ្តាលឱ្យពួកគេងាយនឹងក្លាយជាជនរងគ្រោះពីការ កេងប្រវ័ញ្ចពលកម្ម ។

### ភាពទីទ័លក្រ

ជាការពិតណាស់ ភាពក្រីក្រជាមូលហេតុត្រូវបង្ខំឱ្យកុមារធ្វើការ ។ គ្រួសារក្រីក្រត្រូវការប្រាក់ ហើយក្មេងៗអាចរកចំណូលបានពី ២០ ទៅ ២៥% ។ គ្រួសារដែលក្រីក្រទាមទារចំណាយភាគច្រើន គឺទៅលើម្ហូបអាហារ ។ ចំណាយនេះបញ្ជាក់ឱ្យឃើញច្បាស់លាស់ថា ចំណូលដែលរកបានគឺសម្រាប់ផ្គត់ផ្គង់ការរស់នៅរបស់ពួកគេ ។ ទោះបីយ៉ាងណាក៏ដោយ គេមិនអាចនិយាយថា ភាពក្រីក្រជាមូលហេតុចម្បងរបស់កុមារពលកម្មឡើយ ។ មានរូបភាពផ្សេងៗខុសគ្នាក្នុងគ្រួសារក្រីក្រភាពច្រើន យ៉ាងហោចណាស់ក៏មានកុមារម្នាក់បានចូលរៀនដែរ ។ ប្រហាក់ប្រហែលគ្នានេះដែរ មានតំបន់មួយចំនួនក្នុងប្រទេសក្រីក្រដែលមានពលកម្មកុមាររស់ នៅបានអនុវត្តរបៀបនេះ ប៉ុន្តែប្រទេសក្រីក្រដទៃទៀតពុំបានធ្វើរបៀបនេះឡើយ ។ ឧទាហរណ៍ នៅរដ្ឋ Kerala ប្រទេសឥណ្ឌា

ថ្វីបើប្រទេសនេះក្រក៏ដោយក៏គេធ្វើការលុបបំបាត់ពលកម្មកុមារដែរ ។ ប្រទេសដទៃទៀតក្រដូចគ្នាដែរ ហើយពុំទាន់បញ្ជាក់ច្បាស់លាស់នូវកំរិតខ្ពស់ ឬ ទាបនៃកុមារពលកម្មនៅឡើយ ។

**ទំនៀមទម្លាប់**

ការពិតនៅក្នុងតំបន់នីមួយៗមានទំនៀមទម្លាប់ឱ្យក្មេងៗដើរតាមគន្លងរបស់ឪពុកម្តាយ ។ នៅក្នុងគ្រួសារណាមួយដែលធ្លាប់រកស៊ីបកស្បែកសត្វ កូនក៏អញ្ចឹងដែរ ពួកគេនឹងបន្តការងារតាមរបរនេះដូចគ្នា ។

នៅក្នុងផ្នែកឧស្សាហកម្ម ការចំណាយប្រាក់ឱ្យកម្មករគឺផ្អែកតាមកំរិតការងារដែលគេអនុវត្ត ។ ជាញឹកញាប់ពួកគេអំពាវនាវឱ្យជួយសមាជិកគ្រួសាររបស់ពួកគេដោយផ្តល់ការងារសំណង់ ឬការងារតាមផ្ទះជាដើម ។

**លក្ខណៈដែលនាំឱ្យវង្វេង**

កុមារពលកម្មដែលស្ថិតនៅក្នុងស្ថានភាពផ្សងព្រេង គឺកុមារដែលមានប្រភពចេញពីគ្រួសារដែលជួបការលំបាក ។ គ្រួសារទាំងនោះមានចំណូលទាប មិនតែប៉ុណ្ណោះត្រូវលៃលកប្រាក់កាសខ្លះសម្រាប់ព្យាបាលរបួស ឬជម្ងឺទៀតផង ។ ម្យ៉ាងទៀតគ្រួសារនោះត្រូវមេគ្រួសារបោះបង់ចោល ឬកាលែងលះគ្នា ។ គ្រួសារទាំងនោះអាចជំពាក់បំណុល និងស្ថិតក្រោមការគំរាមកំហែង ដូច្នេះគ្រួសារនោះត្រូវប្រើប្រាស់ក្មេងៗលក់ដើម្បីសងបំណុល ។ កត្តាទាំងនេះ ហើយដែលជាដើមហេតុជំរុញ ឱ្យកើតមានកុមារពលកម្ម ។

**សំណើដើម្បីជួយកុមារពលកម្ម**

អ្នកដែលជួលកម្មករចូលចិត្តជួលក្មេងៗ ពីព្រោះពួកគេមានតម្លៃថោកជាងមនុស្សធំ ហើយពួកគេពុំបង្កភាពរឹងរូស និងមានការទាមទារច្រើនពេកឡើយ ។ ដូច្នេះកុមារពលកម្មទទួលប្រាក់កម្រៃតែពាក់កណ្តាលនៃកំលាំងពលកម្មតែប៉ុណ្ណោះ ។ ការស្រាវជ្រាវទៅលើមូលហេតុកុមារពលកម្មគឺប្រមូលផ្តុំផ្តោតលើការផ្គត់ផ្គង់ពីព្រោះភាពក្រីក្រគឺជាកម្លាំងជំរុញឱ្យមានបញ្ហាច្រើនជាងអ្វីៗទាំងអស់ ។ ប៉ុន្តែការស្នើសុំដើម្បីជួយកុមារពលកម្មក៏ត្រូវតែយកមកគិតជាការចាំបាច់ណាស់ ។ តើហេតុអ្វីបានជាគេជួលកុមារពលកម្ម ?

ជាទូទៅគេតែងបានបកស្រាយថា វាមានតម្លៃថោក ហើយមានភាពប៉ិនប្រសប់រហ័សរហួន ជាការពិតណាស់ អំនះអំណានទាំងពីរនេះមិនអាចបញ្ជាក់ជាភស្តុតាងនៃការធ្វើវិភាគរបស់អង្គការពលកម្មកុមារអន្តរជាតិបានឡើយ ។

អង្គការពលកម្មកុមារអន្តរជាតិបានសន្និដ្ឋានថាការនិយាយពី " ភាពប៉ិនប្រសប់រហ័សរហួន "របស់កុមារសុទ្ធតែជាការលាក់កំបាំងបំភាន់ដែលមាននៅក្នុងផ្នែកឧស្សាហកម្ម ដូចជារោងចក្រផលិតកែវ រោងចក្រផលិតកំរាលព្រំ កន្លែងរុករករ៉ែ ថ្ម ថ្មកំបោរ រោងចក្រផលិតសោរ និងកន្លែងផ្នែតត្បូង ។ល។ នៅក្នុងរោងចក្រឧស្សាហកម្មទាំង នោះសកម្មភាពការងារច្រើនធ្វើដោយក្មេងៗតែក៏ត្រូវមានមនុស្សធំធ្វើការអែបជិតផងដែរ ។

ជាការពិតក្មេងៗភាគច្រើន ពុំមានជំនាញការងារឡើយ ។ សូម្បីតែនៅក្នុងរោងចក្រផលិតកំរាលព្រំ

ការសិក្សាស្រាវជ្រាវទៅលើអ្នកតំបាញជាង ២០០០ បង្ហាញឱ្យឃើញថាក្មេងៗទាំងនោះពុំទាន់មានជំនាញលើស មនុស្សធំឡើយ ។ មិនតែប៉ុណ្ណោះកំរាលព្រំដែលល្អៗភាគច្រើនត្បាញដោយមនុស្សធំ ។ ប្រសិនបើមិនបានឃើញ ស្នាដៃទាំងនោះទេ យើងពិបាកធ្វើការអះអាងថា វិជ្ជាជីវៈរបស់ពួកកុមារអាចយកជាការបាន ឬមិនបាននោះ ណាស់ ។ ពួកគេក៏បានជជែកគ្នាផងដែរអំពីបញ្ហាសេដ្ឋកិច្ច ដែលទាក់ទងនឹងការផ្តល់កម្រៃទៅកុមារថោកជាង មនុស្សធំ ។ រឿងរ៉ាវសន្សំសំចៃមិនមែនជារឿងជាក់ស្តែងឡើយ ប៉ុន្តែការបង្ខិតបង្ខំគឺជារឿងរ៉ាវពិត ។ អង្គការ កុមារពលកម្មអន្តរជាតិបានរកឃើញថា តម្លៃប្រាក់កម្រៃពីការលក់កំរាលព្រំ ឬកងដៃដែលគេក្រងលក់ទៅឱ្យ អតិថិជនទទួលបានប្រាក់កម្រៃទាបគួរឱ្យភ្ញាក់ផ្អើលគឺ កងដៃដែលក្រងលក់បានតិចជាង៥% ឯព្រំបានតម្លៃឋិត ក្នុងចន្លោះពី៥% ទៅ ១០% ។ ដោយផ្អែកលើតម្លៃនេះ គេអាចប្រើតែមនុស្សធំក៏បានដែរ ។ ក៏ប៉ុន្តែហេតុអ្វីក៏គេ ជួលក្មេងទៅវិញ? ចម្លើយក្នុងរឿងទទួលប្រាក់កម្រៃគឺជាការកុហក ឧទាហរណ៍ ករណីផលិតព្រំ គឺពួកគេមាន កីខ្លួនឯងស្រាប់ ហើយពួកគេដោះស្រាយអំបោះ សម្រាប់ត្បាញផ្ទាល់ខ្លួន ។

អ្នកម្ចាស់ត្បាញនៅតែមានជីវភាពក្រលំបាកដោយការផលិតមានទ្រង់ទ្រាយតូច ម្លោះហើយត្រូវចំណាយ ឱ្យកាន់តែតិចសម្រាប់ជួលកុមារទាំងនោះ ។ ដើម្បីឱ្យមានការងាយស្រួលក្នុងការកំណត់តម្លៃលក់ ដើម្បីឱ្យបាន ចំណេញ ។

ការពាក់ព័ន្ធនឹងបញ្ហាតម្លៃជួលកុមារថោក ពុំមែនជាកត្តាសំខាន់ ដើម្បីធ្វើការប្រកួតប្រជែងតម្លៃទីផ្សា ឡើយ ។ តាមការសិក្សាបានលើកបញ្ជាក់ថា រាល់ផ្នែកឧស្សាហកម្មទាំងនោះគ្មានពឹងផ្អែកលើតម្លៃជួលកុមារ ពលកម្ម ដើម្បីធ្វើការប្រកួតប្រជែងឡើយ ។

យ៉ាងណាក៏ដោយ ទីផ្សាសេរីត្រូវលុបបំបាត់កុមារពលកម្ម ហើយជាការប្រសើរទៅទៀតបើអ្នកផលិត កំរាលព្រំទៅរកស៊ីអ្វីផ្សេងទៀត ប៉ុន្តែទោះយ៉ាងណាក៏ដោយផ្នែកឧស្សាហកម្មនៅតែត្រូវការកម្មករ ។ ដូច្នេះហើយ ទើបសកម្មភាពការងារអន្តរជាតិមិនចង់ឱ្យមានការប្រើប្រាស់កុមារពលកម្មនៅក្នុងផ្នែកឧស្សាហកម្ម ។

ការស្វែងយល់ជាច្រើនបង្ហាញឱ្យឃើញថា មូលហេតុធំជាងគេក្នុងការជួលក្មេងៗហាក់ដូចជាមិនមែនពាក់ ព័ន្ធនឹងសេដ្ឋកិច្ចឡើយ ។

ជារួម ក្មេងៗទាំងនោះងាយស្រួលគ្រប់គ្រងដោយសារពួកគេយល់ដឹងអំពីច្បាប់បានតិចតួចមិនសូវមាន រឿងនាំឱ្យខ្វល់ច្រើន ឆាប់ធ្វើតាម ឆាប់ជឿទុកចិត្ត និងធ្វើការពុំសូវឈប់ ។

ចំនុចទាំងនេះបញ្ជាក់ដល់ក្រុមពិភាក្សាឱ្យយល់ច្បាស់ រួចបន្ទាប់មកសួរស្ទាបស្ទង់ប្រតិកម្មទឹកចិត្តរបស់ ពួកគេ ។ តើចំពោះរាល់ចំនុចទាំងអស់នេះ ពួកគេមានអារម្មណ៍ដូចម្តេច ? តើពួកគេមានកំហឹង ឬទេ? តើពួកគេ ជឿឬទេ? វាហាក់ដូចជាគ្មានចិត្តមេត្តាសោះក្នុងការប្រើប្រាស់ក្មេងៗយ៉ាងអាក្រក់បែបនេះ ។ ជាការពិតណាស់ ក្រុមរបស់អ្នក ប្រាកដជាមានអារម្មណ៍អំពីរឿងខាងលើនេះ ។

**ផលប៉ះពាល់នៃការងារមកលើកុមារ**

ដោយសារសរីរាង្គកាយរបស់កុមារ និងរបស់មនុស្សធំមានលក្ខណៈខុសគ្នា ការលូតលាស់ក៏ខុសគ្នាទៀត ពួកគេងាយនឹងទទួលរងនូវជម្ងឺ និងគ្រោះថ្នាក់ការងារជាងមនុស្សធំ ។

ម្យ៉ាងទៀតពួកគេពុំទាន់មានការពិចារណាហ្មត់ចត់ ហើយពួកគេប្រថុយជាមួយនឹងលក្ខខណ្ឌការងារប្រកបដោយគ្រោះថ្នាក់ដែលមានអនុភាពបំផ្លិចបំផ្លាញការលូតលាស់រាងកាយ និងសុខភាពរបស់ពួកគេ ។

ឥទ្ធិពលការងារដែលជះមកលើសរីរាង្គកាយយ៉ាងធ្ងន់ធ្ងរ ដូចជាលើក ឬយួររបស់វត្ថុធ្ងន់ៗ ឬក៏ប្រឹងធ្វើការហួសពីលក្ខណៈធម្មតាដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ពិការរាងកាយ ។ មានភស្តុតាងរួចមកហើយគឺ កុមាររងការឈឺចាប់ដោយសារគ្រោះថ្នាក់ដែលបណ្ដាលមកពីជាតិគីមី និងការភាយចំហាយវិទ្យុសកម្មច្រើនជាងមនុស្សធំពីព្រោះពួកគេពុំមានវិធានការទប់ទល់ចំពោះជម្ងឺឡើយ ។

កុមារទទួលរងការឈឺចាប់ជាងមនុស្សធំ លើករណីរំលោភផ្លូវភេទ និងអារម្មណ៍ព្រមទាំងរងការកេងប្រវ័ញ្ចការសង្កត់សង្កិន ។ អ្វីៗទាំងអស់នេះ គឺជារឿងពិតដែលបានកើតឡើងចំពោះកុមារ និងក្មេងស្រី ។ បញ្ហានានាដែល កើតឡើងចំពោះក្មេងស្រីមានដូចខាងក្រោមនេះ :

- ចាប់ផ្ដើមធ្វើការឆាប់រហ័សជាងក្មេងប្រុស
- ការងារដូចគ្នាតែទទួលប្រាក់កម្រៃតិចជាងក្មេងប្រុស
- ពេលវេលាធ្វើការយូរទទួលបានប្រាក់កម្រៃតិច
- ធ្វើការក្នុងផ្នែកឧស្សាហកម្មដែលលួចលាក់ និងមិនទៀងទាត់ច្បាស់លាស់ ។ ពួកគេភាគច្រើនរងការឈឺចាបដោយសារអាជីវកម្មផ្លូវភេទ ។
- ត្រូវបាននាំយកទៅធ្វើការក្នុងរោងចក្រឧស្សាហកម្ម ដែលប្រកបដោយគ្រោះថ្នាក់ហួសប្រមាណសម្រាប់សុខភាព សុខមាលភាព សុវត្ថិភាពរបស់ពួកគេ ។
- មិនបានចូលសាលារៀន ហើយថែមទាំងទទួលបន្ទុកការងារផ្ទះសម្បែងការងាររកស៊ីទៀត ។

គ្រោះថ្នាក់ខ្លាំងជាងគេបំផុតដែលប៉ះពាល់ចំពោះការរស់នៅ សុខភាព និងសុវត្ថិភាពគឺផ្នែកការងារកសិកម្មដែលមានអាត្រាភាគរយខ្ពស់នៃកុមារពលកម្ម ។ ករណីគ្រោះថ្នាក់ទាំងនោះកើតឡើងដោយឥទ្ធិពលអាកាសធាតុ ការងារធ្ងន់ធ្ងរពេកសម្រាប់រាងកាយកុមារដូចជាមុតនឹងឧបករណ៍កាត់ផ្សេងៗ ជួនកាលប៉ះពាល់ដល់មុខមាត់កុមារថែមទៀត ។ បច្ចេកទេសកសិកម្មកាន់តែទំនើប កាន់តែនាំមកនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ពួកគេ ឧទាហរណ៍ ការប្រើប្រាស់ ជាតិថ្នាំគីមី និង ឧបករណ៍ម៉ាស៊ីនផ្សេងទៀត ។

កុមារជាច្រើនត្រូវស្លាប់ដោយសារគ្រាក់ទ័រកិន ឬឡានកុងទីន័របើកកិនក្នុងការដឹកជញ្ជូនតាមកសិដ្ឋាន ។

នៅក្នុងប្រទេសភាគច្រើន ការប្រឈមមុខនឹងគ្រោះថ្នាក់ចំពោះសុខភាពកើតឡើងដោយសារភាពក្រីក្រ និង ខ្វះខាតការអប់រំ គ្មានផ្ទះសម្បែង ខ្វះអនាម័យ អាហារហូបចុកពុំគ្រប់គ្រាន់ដើម្បីធ្វើការ ។ ច្បាប់ការពារសិទ្ធនៅក្នុងការងារផ្នែកកសិកម្មមិនទាន់កំណត់ត្រឹមត្រូវ ។

ប្រទេសជាច្រើនបានកំណត់ការងារដែលកុមារធ្វើគឺធ្វើដូចការងារក្នុងគ្រួសារដែរ ។ សូម្បីតែនៅពេលដែលមានច្បាប់ហើយក៏ដោយ កុមារពលកម្មនៅតែប្រឈមមុខនឹងការបង្ខិតបង្ខំដោយសារស្ថានភាពភូមិសាស្ត្រនៃឧស្សាហកសិកម្មស្ថិតនៅរប៉ាត់រប៉ាយ ។

## ហេតុអ្វីបានជាត្រូវបញ្ឈប់ពលកម្មកុមារ ?

- ពលកម្មកុមារគឺ ជាការងារមួយបណ្តាលឱ្យមានការបំផ្លិចបំផ្លាញ និងផ្តល់នូវគ្រោះថ្នាក់យ៉ាងច្រើន ថែមទាំងជាបទល្មើសចំពោះច្បាប់ការងារជាតិ និងអន្តរជាតិ ។
- សកម្មភាពការងារប៉ះពាល់ដល់មនសិកា សរីរាង្គកាយ សង្គម គ្រោះថ្នាក់ដល់ផ្លូវចិត្ត និងធ្វើឱ្យមានទុក្ខដល់កុមារ ។
- ជាមួយគ្នានេះដែរ ការងារទាំងនោះបង្ខាំងគេពុំឱ្យទៅសាលារៀន ដោយសារពួកគេត្រូវទទួលបន្ទុកការងារ
- ម្យ៉ាងទៀតការងារបានបង្ខំឱ្យពួកគេក្លាយជាទាសករ ហើយបំបែកពួកគេចេញពីគ្រួសាររបស់ពួកគេ ។
- ការងារបានបង្កឱ្យកុមារ និងគ្រួសាររបស់ពួកគេធ្លាក់ចុះទៅរកភាពក្រីក្រកាន់តែខ្លាំងឡើង
- សភាវៈមនុស្សតែងទោរទន់ទៅតាមអារម្មណ៍ និង ស្មារតីដោយឡែកកុមារបែរជាប្រឈមមុខនឹងការងារផ្ទុយនឹងក្រឹត្យក្រម ។
- ការអង្កេតថ្នាក់ជាតិបានបង្ហាញឱ្យឃើញថា កុមារដែលមានរបួស ឬ ក៏ធ្លាក់ខ្លួនឈឺពេលកំពុងធ្វើការមានទំហំកាន់តែខ្ពស់ឡើងៗ ។ កុមារខ្លះពុំអាចធ្វើការបន្តទៅទៀតបាន ។
- ក្នុងការងារដែលមានការពាក់ព័ន្ធជាមួយការប្រើប្រាស់ឧបករណ៍ម៉ាស៊ីនដូចជា ផ្នែកកសិកម្មជាដើម ក៏រិតនៃគ្រោះថ្នាក់ ឬរបួសមានកាន់តែខ្ពស់ខ្លាំងឡើង ។
- ក្នុងផ្នែកកសិកម្ម ការរុករករ៉ែ គឺជាការងារមួយប្រថុយជាមួយនឹងគ្រោះថ្នាក់សម្រាប់កុមារពលកម្មខ្លាំងណាស់ ។

## ឧបសម្ព័ន្ធ៣

### ឧទាហរណ៍អំពីការងារនានាដែលប្រឈមមុខនិងគ្រោះថ្នាក់

| ការងារ ផ្នែកឧស្សាហកម្ម | សកម្មភាពការងារ | គ្រោះថ្នាក់ផ្សេងៗ ដែលកើតឡើង | ផលវិបាក ដែលកើតមានឡើង |
|---|---|---|---|
| ការរុករករ៉ែ Mining | ជីករុករកក្រោមដីដោយ រែក ឬ យួរធ្ងន់ៗ | គ្រោះថ្នាក់បណ្តាលមកពីកំទេចធូលីហ្គាស ផ្សែង សំណើមខ្លាំង និងកំរិតសីតុណ្ហភាពប្រែប្រួលស្ថានភាពធ្វើការពុំស្រួល ( អោន លុត ជង្គង់ តោង) ក្នុង រូងភ្នំ ។ | ជម្ងឺផ្លូវដង្ហើមដែលបណ្តាលឱ្យទៅជាជម្ងឺសួតរ៉ាំរ៉ៃ ជម្ងឺក្រិនសាច់សួត ជម្ងឺធ្លាយថង់សួត ជម្ងឺសាច់ដុំឆ្អឹង និងការស្លាប់ដោយសារធ្លាក់ចូលក្នុងរូងភ្នំ ។ |
| វាយបំបែកថ្ម Brick making | វាយកំទេចបំបែកថ្ម កិនរែង គាស់ថ្ម | គ្រោះថ្នាក់ដោយសារកំទេចធូលីសារ ធាតុ Silicate ជាតិសំណកាបូន monoxide សែងថ្ម ធ្ងន់ៗ ហួសប្រមាណកំដៅក្តៅដែលជះពីឡគ្រោះថ្នាក់ដែលបង្កដោយឧបករណ៍ប្រើប្រាស់ | មានរបួសប៉ះពាល់សរសៃសាច់ដុំ |
| កសិកម្ម Agriculture | ធ្វើការដោយម៉ាស៊ីនគ្រឿងឧបករណ៍កសិកម្មជាមួយសត្វពាហនៈ ការប្រមូលផលិតផលគ្រាប់ពូជ ។ | គ្រឿងម៉ាស៊ីនមិនធានាសុវត្ថិភាពគ្រោះថ្នាក់បន្ទាប់បន្សំផ្សេងទៀតមានថ្នាំសម្លាប់សត្វល្អិត ថ្នាំបំផ្លាញស្មៅ ការលើករបស់ធ្ងន់ៗ ផលប៉ះពាល់ពីអាកាសធាតុ | ពុលថ្នាំគីមី ( រ៉ាំរ៉ៃខ្លាំងឡើងៗ ) មុតនឹងរបួសខ្លួនប្រាណ មានជម្ងឺ |
| ត្បាញកម្រាលព្រំ Carpet Wearing | ត្បាញ ក្រងព្រំ ដោយកីតម្បាញ | ស្រូបយកព្រុយធូលី ដែលកខ្វក់ពីអំបោះត្បាញ សារធាតុគីមីដែលមាននៅក្នុងអំបោះ ធ្វើការអង្គុយចោងហោង ឈរ ឬអង្គុយយូរពន្លឺពុំគ្រប់គ្រាន់ ខ្យល់ចេញចូលពុំគ្រប់គ្រាន់គ្រោះថ្នាក់ដោយសារធាតុគីមី | ជម្ងឺផ្លូវដង្ហើម ជម្ងឺសរសៃសាច់ដុំ រោយភ្នែក និងឆាប់ងងឹតមុនអាយុ ពុលថ្នាំគីមី ជម្ងឺកាន់តែដុនដាប ។ |

| | | | |
|---|---|---|---|
| ការងារសាងសង់ Contruction Work | ជីកដី យួរដី បំបែកថ្ម ចូកខ្សាច់-ស៊ីម៉ងត៍ ការងារពាក់ព័ន្ធនឹងការស្លដែក | គ្រោះថ្នាក់ដោយធ្លាក់របស់របរជាន់ ឬ មុតនឹងរបស់ស្រួចៗ ធ្លាក់ពីទីខ្ពស់ ស្រូបយកធូលី ក្តៅ មានសម្លេងខ្លាំង លើករបស់ធ្ងន់ៗ | ធ្វើឱ្យសុខភាពអន់ថយដោយសារសម្លេងញ៉ូរ គ្រោះថ្នាក់ របួស រឺស្លាប់ដោយការធ្លាក់ ជួនកាលពិការធ្វើការលែងកើត |
| កន្លែងសម្លាប់សត្វយកស្បែក Tannery | បកស្បែក និងការពាររក្សាស្បែកទុក | មេរោគស៊ី ឬកាត់ដៃដោយសារបាក់តេរី និងជាតិក្រខ្វក់ចូលក្នុងដៃ | ជម្ងឺជីវសាស្ត្រប៉ះពាល់ស្បែក និងធ្វើ ឱ្យឆ្លងទៅជាដំបៅ |
| ការនេសាទត្រីសមុទ្រ Deep-Sea Fishing | មុជរាវចូលក្នុងជម្រៅទឹក ៦០ ម៉ែត្រ អូសសំណាញ់ ចងនឹងថ្ម ប៉ប្រះទឹក | ទទួលរងនូវសម្ពាធទឹកជ្រៅពេក គ្រោះថ្នាក់ដោយសារត្រីដែលស៊ីសាច់ជាអាហារ និងសត្វសមុទ្រដែលមានជាតិ ពុល ។ គ្រោះថ្នាក់ដោយសារគ្មានអនាម័យ និងស្ទះខ្យល់ដកដង្ហើម ។ | ជម្ងឺសង្កត់សរសៃឈាមរហែក ក្រដាសត្រចៀក ស្លាប់ ឬរបួស ។ ជម្ងឺពាក់ព័ន្ធពោះវៀន ។ |
| រោងចក្រកែវ Glass Factory | ចាក់ពុម្ពកែវដែលនៅក្តៅៗ | ទីកន្លែងបញ្ចេញកំដៅក្តៅខ្លាំង ប៉ះពាល់ នឹងផ្សែងពុលធូលីមានជាតិ Silica មុតដៃជើងដោយជាន់ ឬ កាន់អំបែងកែវ ។ | ប៉ះទង្គិចខ្លាំងរហូតដល់របួសភ្នែក ក្តៅខ្លាំងពេកមានជម្ងឺរលាកផ្លូវដង្ហើម រលាកភ្លើង និងមុតដៃជើង |
| ធ្វើឈើគូសនិងកាំជ្រួច Matches and Firework | ច្របល់ជាតិគីមីក្តៅៗ ដែលគេចំហុយធ្វើឈើគូសដោយលាយម្សៅម្យ៉ាងធ្វើកាំជ្រួច | គ្រោះថ្នាក់បណ្តាលមកពីជាតិគីមីការផ្ទុះ និងភ្លើងឆេះរលាក | សារធាតុគីមី Syneigistic ធ្វើឱ្យពុល មានជម្ងឺផ្លូវដង្ហើម ធ្វើឱ្យរលាក របួស និងស្លាប់ដោយការផ្ទុះផ្សេងៗ |
| ការកកាយសំរាម Scavenging | ការងារដែលចុះទៅធ្វើជាកន្លែង ដែលគ្មានអនាម័យ ប្រមូលទាញ យកវត្ថុដែលអាចប្រើការបានពីគំនសំរាម កាកសំណល់កខ្វក់ចេញពីមន្ទីពេទ្យ ។ | មុតដោយសារអំបែងកែវ ឬដែកច្រេស ដង្ហើមចេញចូលស្រូបនូវក្លិនវត្ថុដែល ស្អុយរលួយរុយរោមពាសពេញ បរិភោគអាហារជូរផ្អូម | របួសដល់ស្លាប់ ដោយសារជម្ងឺតេតាណូស សារជាតិពុលបណ្តាលឱ្យកើតជម្ងឺឆ្លងផ្សេងៗ ឆេះរលាកដោយផ្ទុះ ជាតិឧស្ម័នមេតាន |

| | | | |
|---|---|---|---|
| ការផលិតបន្ទះក្តារ Slate Making | យូរឈើធូន់ៗមកកាត់ធ្វើក្តារ ខ្មៅដៃ និងក្តារឆ្នួន។ | គ្រោះថ្នាក់ដោយសែងក្តារធ្ងន់ៗ ពេក ប៉ះពាល់ដោយហុយធូលី | ជម្ងឺសាច់ដុំសរសៃ ជម្ងឺសួត និងបាត់បង់សមត្ថភាពធ្វើការមុនអាយុ |

### គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក តូច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប តឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

### គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក តូច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប តឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡង់ សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

### គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុធារី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី គុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ហ៊ៀម ភិណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស៊្រុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី ឈី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

### គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់មិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក វង់ សុវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ តង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស៊្រុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

### គណៈកម្មការហិរញ្ញ និងគាំទ្រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សូច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# ✕ បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


### សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាធីរ ប៉ូល យុសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង នរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់(TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗនិងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៥ ២៥៨**

**Email** : **nfe@camnet.com.kh**



ISBN-9789995088217
9 789995 088217